**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ១៧១៤ ព.ណ.វ.ប.ព.ស

ថ្ងៃព្រហស្បតិ៍ ១១រោច ខែពិសាខ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី

**- ការចាប់ផ្តើមចូលរៀនវគ្គបណ្តុះបណ្តាលអ្នកតំណាងស្របច្បាប់ ក្នុងការស្នើសុំឯកសារនាំចេញ-នាំចូល ជំនាន់ទី៣ និង**
**- ចាប់ផ្តើមទទួលពាក្យសម្រាប់វគ្គបន្តបន្ទាប់ នៅក្រសួងពាណិជ្ជកម្ម**

ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជាមានកិត្តិយសសូមជម្រាបជូនដល់សិក្ខាកាមទាំងអស់ឲ្យបានជ្រាបថា៖ ក្រសួងពាណិជ្ជកម្មនឹងរៀបចំវគ្គបណ្តុះបណ្តាលលើកទី៣ សម្រាប់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំឯកសារនាំចេញ-នាំចូលជំនាន់ទី៣ សរុបចំនួន **៦៥នាក់** ដែលនឹងប្រព្រឹត្តទៅចាប់ពី **ថ្ងៃចន្ទ ៧កើត ដល់ ថ្ងៃចន្ទ ១៣រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ដល់ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ១:៣០ ដល់ ៥:៣០នាទី រសៀល** នៅសាលប្រជុំបន្ទាយឆ្មា (ជាន់ទី៤ អគារC) ទីស្តីការក្រសួងពាណិជ្ជកម្ម។

វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងក្នុងគោលបំណងដើម្បីគ្រប់គ្រង និងពង្រឹងសមត្ថភាពអ្នកតំណាង ស្របច្បាប់របស់សហគ្រាស ក្រុមហ៊ុន អោយបានជាអតិបរមា ព្រមទាំងពង្រឹង និងបង្កើនប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ ប្រកាស សេចក្តីជូនដំណឹងផ្សេងៗ ពាក់ព័ន្ធនឹងការផ្តល់ឯកសារនាំចេញ-នាំចូល ជាពិសេសគាំទ្រដល់ការផ្តល់សេវានាំចេញនាំចូលឲ្យកាន់តែប្រសើរឡើងដូចបានកំណត់ក្នុងប្រកាសលេខ ២៥៨ ព.ណ ចបព.ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការទទួលស្គាល់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ឬ ឯកសារនាំចេញ-នាំចូលនៅក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

បញ្ជាក់៖ -សូមអញ្ជើញមកពិនិត្យឈ្មោះនៅ វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ (TTRI) ជាន់ទី១ អគារ A នៃក្រសួងពាណិជ្ជកម្ម។

-ការចែក និងការទទួលពាក្យ ចូលរៀនសម្រាប់វគ្គបន្តបន្ទាប់នឹងទទួលចាប់ពីថ្ងៃជូនដំណឹងនេះតទៅ នៅរៀងរាល់ម៉ោងធ្វើការ។

*ទំនាក់ទំនង៖*
*០៩២ ១៣៦ ៦៩៩*
*០១៦ ៩៩៩ ២០០៩*

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469